**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
លេខ : ០៩៥ អ.ជ.ប.ជ.អ./លៈ ៩

ភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤

# ប្រកាស
# ស្តីពី
# របៀបរបបការងារ និង ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩៤២ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៦៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង ការតែងតាំងបន្ថែមសមាសភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរជាត្រិយុទ្ធនឹងជំងឺអេដស៍
- តាមការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## សម្រេច

ប្រការ ១ .- កំណត់របៀបរបបការងារ និង បែងចែកភារកិច្ចជូនប្រធាន អនុប្រធាន និង ទីប្រឹក្សាសំដៅធានាការអនុវត្តច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ និង ដឹកនាំកិច្ចការទូទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដូចមានចែងក្នុងប្រការខាងក្រោម ។

ប្រការ ២.- ប្រធានទទួលបន្ទុកដឹកនាំការងាររួម និង ចាត់ចែងបណ្ដារាល់សកម្មភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

ប្រការ ៣.- អនុប្រធាន ៖

១. ឯកឧត្តម **ម៉ម ប៊ុនហេង** អនុប្រធានទី១ ទទួលបន្ទុកជួយប្រធានលើការងារសម្របសម្រួល និង សហការជិតស្និទ្ធរវាងក្រសួងសុខាភិបាល និង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ។

២. ឯកឧត្តមសាស្ត្រាចារ្យ **លី ប៉ូវ** ទទួលបន្ទុកជាអនុប្រធានប្រចាំការ និង ជាប្រធានស្ដីទី ពេលអវត្តមានប្រធាន ។

៣. ឯកឧត្តម **ស៊ឹម គឹមសែន** ទទួលបន្ទុកជួយប្រធានក្នុងការងារឃ្លាំមើល និង វាយតម្លៃលើរាល់កម្មវិធីនៃការប្រយុទ្ធនឹងជំងឺអេដស៍ (Monitoring and Evaluation) ។

៤. ឯកឧត្តម **អ៊ឹង វុទ្ធី** ទទួលបន្ទុកជួយប្រធានក្នុងការសម្របសម្រួលការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន និង ចូលរួមជួយការងារយុទ្ធសាស្ត្រជាតិកសាងមគ្គុទ្ទេសក៍ភាព ឬ ភាពជាអ្នកដឹកនាំ និង អភិវឌ្ឍន៍ស៊ីណេស៊ី ។

៥. ឯកឧត្តម **កៅ ទ្រី** ទទួលបន្ទុកជួយប្រធានក្នុងការងារយុទ្ធសាស្ត្រជាតិ ជួយកសាងមគ្គុទ្ទេសក៍ភាព ឬ ភាពជាអ្នកដឹកនាំស៊ីណេស៊ី ព្រមទាំងតាមដានសម្របសម្រួលការងារប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្ដីការគណៈរដ្ឋមន្ត្រី នៃក្រសួង និង រដ្ឋលេខាធិការដ្ឋានទាំងអស់ លើកលែងតែក្រសួងកិច្ចការនារី ។

៦. ឯកឧត្តម **ទា ផលា** ទទួលបន្ទុកជួយប្រធានក្នុងការសម្របសម្រួលយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ។

៧. ឯកឧត្តម **គង់ វដ្ឋា** ទទួលបន្ទុកការងារខុទ្ទកាល័យ ។

៨. លោកជំទាវ **ស៊ឹម ខេងខាំ** ទទួលបន្ទុកជួយប្រធានក្នុងការងាររដ្ឋបាលផ្នែកបុគ្គលិក និង ជួយតាមដានសម្របសម្រួលការងារប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ រាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង និង ក្រសួងកិច្ចការនារី ។

៩. ឯកឧត្តម **ជា សំអាន** ទទួលបន្ទុកជួយប្រធានក្នុងការងារសម្របសម្រួលការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍សម្រាប់ខេត្តបន្ទាយមានជ័យ ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តក្រចេះ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និង

ចូលរួមជួយការងារយុទ្ធសាស្ត្រជាតិកសាងមត្តទ្វេសក៏ភាព ឬ ភាពជាអ្នកដឹកនាំ និង អភិវឌ្ឍស៊ីណេស៊ី ។

ប្រការ ៤.- ទីប្រឹក្សា ៖

១. ឯកឧត្តម **ថៃ ហ្វា** ជួយការងារទំនាក់ទំនងសាធារណៈ ទំនាក់ទំនងគណបក្សនយោបាយ និង ការងារសង្គមកិច្ច ។

២. ឯកឧត្តម **ឡឹម ពេជ្ជពិសី** ជួយការងារទំនាក់ទំនងជាមួយបណ្តាញផ្សព្វផ្សាយជាតិ និង អន្តរជាតិ រួមទាំងបណ្តាញសង្គម និង ជួយការងារបច្ចុប្បន្នភាពសម្រាប់ការផ្សព្វផ្សាយតាមគេហទំព័រ Website របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

៣. ឯកឧត្តម **អ៊ុក វឌ្ឍនា** ជួយការងារច្បាប់ ទំនាក់ទំនងសាធារណៈ និងសង្គមកិច្ច ។

ប្រការ ៥.- អនុប្រធានទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀតដែលប្រធានប្រគល់ជូន ។

ប្រការ ៦.- បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.- អនុប្រធាន នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គលេខាធិការរង គ្រប់ប្រធាននាយកដ្ឋាន និង មន្ត្រីរាជការដូចមានរាយនាមក្នុងប្រការ៤ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

អៀង មូលី

**ចម្លងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល
-ក្រសួងមុខងារសាធារណៈ
-គណៈកម្មាធិការអេដស៍គ្រប់រាជធានី/ខេត្ត
-លេខាធិការដ្ឋានអេដស៍រាជធានី/ខេត្ត
-ដូចប្រការ ៣ និង ៤
-ឯកសារ-កាលប្បវត្តិ